ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និង កីឡា

លេខ ០៥ អយក.ប្រក

# ប្រកាស

## ស្តីពីការបើកអនុវិទ្យាល័យ ជ្រុងស្រឡៅ

## ស្ថិតនៅក្នុងឃុំស្តេចគង់ខាងជើង ស្រុកបន្ទាយមាស ខេត្តកំពត

### រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១១៩៨_៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ នស_៩៤ ចុះថ្ងៃទី ២០ កក្កដា ១៩៩៤ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស_រកម ០១៩៦_០១ចុះថ្ងៃទី ២៤ មករា ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំយុវជន និង កីឡា
- បានឃើញព្រះរាជក្រឹត្យ លេខ នស_រកត ០៧៩៦_៥២ ចុះថ្ងៃទី ២៦ កក្កដា ១៩៩៦ ស្តីពីប្រព័ន្ធអប់រំចំនេះទូទៅ ១២ឆ្នាំ
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ_បក ចុះថ្ងៃទី ២៣ មីនា ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញសារាចរណែនាំលេខ ៦៦ អរ.ចទមចុះថ្ងៃទី ០២ មេសា ១៩៨៣ ស្តីពីការបើកសាលារៀនមធ្យមសិក្សាកំរិត១_កំរិត២
- យោងលិខិតស្នើសុំរបស់សហគមន៍ឃុំស្តេចគង់ខាងជើង ស្រុកបន្ទាយមាស ចុះថ្ងៃទី ១៤ ខែ សីហា ឆ្នាំ ២០០៣ ដោយមានយោបល់ឯកភាពពីមន្ទីរអប់រំ យុវជន និងកីឡា និងអភិបាលខេត្តកំពត
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានមធ្យមសិក្សាចំនេះទូទៅ

### សំរេច

ប្រការ ១ : អនុញ្ញាតអោយបើកអនុវិទ្យាល័យដែលមានឈ្មោះថា : អនុវិទ្យាល័យ « ជ្រុងស្រឡៅ » ស្ថិតនៅក្នុងឃុំស្តេចគង់ខាងជើង ស្រុកបន្ទាយមាស ខេត្តកំពត ចាប់ពីឆ្នាំសិក្សា ២០០៣_២០០៤ តទៅ ។

ប្រការ ២ : អនុវិទ្យាល័យនេះត្រូវដឹកនាំដោយនាយកមួយរូប និងនាយករងតាមការចាំបាច់ ព្រមទាំងបុគ្គលិកផ្សេងៗ មួយចំនួនទៀតតាមអង្គការលេខ នៃអនុវិទ្យាល័យ ។

ប្រការ ៣ : នាយក_នាយករងនៃអនុវិទ្យាល័យមានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ចតាមគោលការណ៍របស់រដ្ឋ ។

ប្រការ ៤ : អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានមធ្យមសិក្សាចំនេះទូទៅ នាយកដ្ឋានបុគ្គលិក នាយកដ្ឋានផែនការ នាយកដ្ឋានហិរញ្ញវត្ថុ ក្រសួងអប់រំ យុវជន និងកីឡា មន្ទីរអប់រំ យុវជន និងកីឡាខេត្តកំពត និងនាយកអនុវិទ្យាល័យសាមីមានភារកិច្ចរៀងៗ ខ្លួនអនុវត្តប្រកាសនេះ ។

ភ្នំពេញ , ថ្ងៃទី ០៥ ខែមករា ឆ្នាំ ២០០៤

ជ.រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

រដ្ឋលេខាធិការ

អ៊ុម សិទ្ធី

**កន្លែងទទួល :**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
 " ដើម្បីជ្រាបជាពតិមាន "
- សាលាខេត្តកំពត " ដើម្បីជាពតិមាន "
- ដូចប្រការ ៤
- កាលប្បវត្តិ_ឯកសារ នា.មចទ

C:\New school\K-kong2.doc